# មេរៀនទី 2 ជំងឺឆ្លង

## វត្ថុបំណង

ដូចដែលបានសរសេរក្នុងសៀវភៅពុម្ព វត្ថុបំណងក្នុងមេរៀននេះមានៈ

- ពន្យល់ពាក្យជំងឺឆ្លង និងមូលហេតុនៃការឆ្លងជំងឺ
- បង្ហាញពីជំងឺកាមរោគ ជំងឺអេដស៍ របៀបឆ្លង និងរបៀបមិនឆ្លងនៃជំងឺទាំងនោះ
- ពណ៌នាពីការការពារខ្លួនកុំឱ្យភ្នាក់ងារបង្ករោគជ្រៀតចូលក្នុងខ្លួនបានដោយអនុវត្តក្បួនអនាម័យក្នុងការបរិភោគ និងការរស់នៅ
- អប់រំចិត្តខ្លួនឯង និងអ្នកដទៃកុំឆាប់ពាក់ព័ន្ធជាមួយសកម្មភាពផ្លូវភេទ
- ពន្យល់ពីផលវិបាកនៃជំងឺឆ្លង និងកាមរោគ ជាពិសេសជំងឺអេដស៍ហើយចៀសវាងការប្រព្រឹត្តិអំពើណាមួយដែលបណ្តាលឱ្យឆ្លងជំងឺ

## ផែនការបង្រៀន

មេរៀននេះត្រូវបង្រៀនរយៈពេល 10 ម៉ោងដូចដែលបានបង្ហាញក្នុងតារាងទី 1 ខាងក្រោមៈ

**តារាងទី1 បំណែងចែកម៉ោងបង្រៀន**

| រយៈពេល (ម៉ោងសរុប = 10 ម៉ោង) | ខ្លឹមសារ | ទំព័រក្នុងសៀវភៅពុម្ព |
|---|---|---|
| 1 | 1. ជំងឺឆ្លង<br>1.1. រោគសញ្ញានៃជំងឺឆ្លងមួយចំនួន | 222 - 223 |
| 1 | 1.2. វិធីការពារកុំឱ្យឆ្លងជំងឺ | 224 |
| 2 | 1.3. តវិយាបថនៃការឆ្លងជំងឺ<br>2. ជំងឺកាមរោគ<br>2.1. ព័ត៌មានទូទៅស្តីពីជំងឺកាមរោគ<br>2.2. ប្រភេទផ្សេងៗនៃជំងឺកាមរោគ<br>2.3. ការព្យាបាលជំងឺកាមរោគ | 225 - 228 |
| 1 | 3. ជំងឺអេដស៍<br>3.1. និយមន័យនៃជំងឺអេដស៍ | 229 |
| 1 | 3.2. ការវិវត្តរបស់ជំងឺអេដស៍ | 230 |
| 1 | 3.3. បណ្តុំរោគសញ្ញាទាក់ទងនឹងដំណាក់កាលអេដស៍<br>3.4. សភាពអ្នកជំងឺអេដស៍ | 231 |
| 1 | 3.5. របៀបឆ្លង និងរបៀបមិនឆ្លងនៃមេរោគអេដស៍ | 232 |
| 1 | 3.6. ការបង្ការមេរោគអេដស៍ និងកាមរោគ<br>3.7. ផលប៉ះពាល់នៃជំងឺអេដស៍ | 233 - 234 |
| 1 | មេរៀនសង្ខេប | 235 |

## សេចក្តីណែនាំសម្រាប់ការបង្រៀន

តារាងទី2 ខាងក្រោមបង្ហាញពីផែនការបង្រៀន និងលទ្ធផលវាយតម្លៃ។ គ្រូត្រូវបានរំពឹងថាអនុវត្តសកម្មភាពក្នុងតារាងខាងក្រោម ហើយធ្វើការវាយតម្លៃសិស្សទៅតាមលក្ខណៈវិនិច្ឆ័យដែលបានឱ្យក្នុងតារាង។ ដូចនៅក្នុងតារាងសិស្សអាចធ្វើការសិក្សាអំពីជំងឺឆ្លង។ សកម្មភាពទាំងនេះជំរុញសិស្សឱ្យមានការអភិវឌ្ឍនូវចំណេះដឹងរបស់ពួកគេអំពីជំងឺឆ្លង។

**តារាងទី2 ផែនការបង្រៀន និងលទ្ធផលវាយតម្លៃ**

| ម៉ោង | វត្ថុបំណង | សកម្មភាពក្នុងរយៈពេលនីមួយៗ | លទ្ធផលវាយតម្លៃ |
|---|---|---|---|
| ទី1 | ពន្យល់ពាក្យ “ជំងឺឆ្លង” និងរបៀបនៃការឆ្លងជំងឺ | • សិស្សពិភាក្សាគ្នាពីជំងឺឆ្លងដែលពួកគេធ្លាប់ស្គាល់។<br>• សិស្សបំពេញពាក្យក្នុងចន្លោះក្នុងតារាង ជំងឺឆ្លង រោគសញ្ញា និងរបៀបឆ្លងជំងឺ ដោយប្រើប័ណ្ណពាក្យ។ | • សិស្សពន្យល់ពាក្យ “ជំងឺឆ្លង” និងរបៀបនៃការឆ្លងជំងឺ |
| ទី2 | ពណ៌នាពីរបៀបការពារខ្លួនកុំឱ្យភ្នាក់ងារបង្ករោគជ្រៀតចូលក្នុងខ្លួនបានដោយអនុវត្តក្បួនអនាម័យក្នុងការបរិភោគ និងការរស់នៅ | • សិស្សរៀបរាប់ពីវិធីការពារខ្លួនពីជំងឺឆ្លង | • សិស្សពណ៌នាពីរបៀបការពារខ្លួនកុំឱ្យភ្នាក់ងារបង្ករោគជ្រៀតចូលក្នុងខ្លួនបានដោយអនុវត្តក្បួនអនាម័យក្នុងការបរិភោគ និងការរស់នៅ |
| ទី3+4 | បង្ហាញពីជំងឺកាមរោគ និងពន្យល់ពីផលវិបាកនៃជំងឺកាមរោគ | • សិស្សបំពេញក្នុងតារាងភ្នាក់ងារបង្កជំងឺ និងរោគសញ្ញាជំងឺកាមរោគដោយប្រើប័ណ្ណពាក្យ<br>• សិស្សបំពេញចន្លោះក្នុងតារាងនៃភ្នាក់ងារបង្កជំងឺ និងរោគសញ្ញាជំងឺកាមរោគដោយប្រើប័ណ្ណពាក្យ | • សិស្សបង្ហាញពីជំងឺកាមរោគ និងពន្យល់ពីផលវិបាកនៃជំងឺកាមរោគ |
| ទី5 | ពន្យល់ពីរបៀបឆ្លង និងរបៀបមិនឆ្លងនៃជំងឺអេដស៍ | • សិស្សពិភាក្សាពីចំណេះដឹងនៃជំងឺអេដស៍ទៅវិញទៅមក។ | • សិស្សពន្យល់ពីរបៀបឆ្លង និងរបៀបមិនឆ្លងនៃជំងឺអេដស៍ |
| ទី6 | ពន្យល់ពីរបៀបឆ្លង និងរបៀបមិនឆ្លងនៃជំងឺអេដស៍ | • សិស្សសង្ខេបពីការវិវត្តរបស់ជំងឺអេដស៍ | • សិស្សពន្យល់ពីរបៀបឆ្លង និងរបៀបមិនឆ្លងនៃជំងឺអេដស៍ |
| ទី7 | ពន្យល់ពីរបៀបឆ្លង និងរបៀបមិនឆ្លងនៃជំងឺអេដស៍ | • សិស្សសង្ខេបពីរោគសញ្ញានៃជំងឺអេដស៍ | • សិស្សពន្យល់ពីរបៀបឆ្លង និងរបៀបមិនឆ្លងនៃជំងឺអេដស៍ |
| ទី8 | ពន្យល់ពីរបៀបឆ្លង និងរបៀបមិនឆ្លងនៃជំងឺអេដស៍ | • សិស្សពិភាក្សាពីរបៀបឆ្លង និងពីរបៀបទាក់ទងជាមួយអ្នកជំងឺអេដស៍ដោយសុវត្ថិភាពតាមរយៈការជ្រើសរើសរូបភាពក្នុងសៀវភៅពុម្ពទំព័រទី 232 និងទំព័រទី 233។ | • សិស្សពន្យល់ពីរបៀបឆ្លង និងរបៀបមិនឆ្លងនៃជំងឺអេដស៍ |

| | | | |
|---|---|---|---|
| ទី9 | ពន្យល់ពីរបៀបឆ្លង និង របៀបមិនឆ្លងនៃជំងឺអេដស៍ | • អាស្រ័យលើក្រាភិច សិស្សឆ្លើយសំណួរ | • សិស្សពន្យល់ពីរបៀបឆ្លង និង របៀបមិនឆ្លងនៃជំងឺអេដស៍ |
| ទី10 | សង្ខេបពីជំងឺឆ្លង | • សិស្សឆ្លើយសំណួរ | • សិស្សសង្ខេបពីជំងឺឆ្លង |

## ចំណុចសំខាន់នៃការបង្រៀន

ចំណុចនៃការបង្រៀនក្នុងមេរៀននេះគឺជំងឺឆ្លង។ ដូច្នេះ គ្រូគួរតែយកចិត្តទុកដាក់ឱ្យបានច្រើនទៅលើចំណុចខាងក្រោមក្នុងពេលបង្រៀនមេរៀននេះ។

- ឱ្យសិស្សពិភាក្សាគ្នាដើម្បីយល់ដឹងពីជំងឺឆ្លង។ វាអាចមានការពិបាកក្នុងការយល់ដឹងពីជំងឺឆ្លង។ ដូចនេះ សៀវភៅណែនាំគ្រូនេះបានបង្ហាញពីជំងឺឆ្លង ដើម្បីជំរុញការយល់ដឹងដល់សិស្ស។
- ត្រួតពិនិត្យចំណេះដឹងមានស្រាប់របស់សិស្សនៅពេលចាប់ផ្តើមមេរៀននីមួយៗ។ ប្រសិនបើ អ្នករកឃើញថាសិស្សពុំទាន់មានចំណេះដឹងគ្រប់គ្រាន់ បន្ទាប់មកពន្យល់បន្ថែម និងបង្ហាញរូបភាពដែលចាំបាច់។
- បំណែងចែកម៉ោងទៅតាមសកម្មភាពដែលបានកំណត់ទុក។ សៀវភៅណែនាំគ្រូនេះណែនាំសកម្មភាពទៅតាមម៉ោងបង្រៀន ប៉ុន្តែគ្រូអាចមានការលំបាកខ្លះចំពោះសកម្មភាពនេះ។

ដូច្នេះ សៀវភៅណែនាំគ្រូនេះផ្តល់នូវគម្រុយខ្លះសម្រាប់ការបង្រៀន (ឧទាហរណ៍៖ សំណួរ និងសកម្មភាព) ក៏ដូចជាចំណេះដឹងបន្ថែមមួយចំនួនអំពីជំងឺឆ្លង ដើម្បីជំរុញការចាប់អារម្មណ៍របស់សិស្សទៅលើការសិក្សា។

## ចំណេះដឹងមូលដ្ឋានសម្រាប់មេរៀននេះ

នៅពេលចាប់ផ្តើមម៉ោងសិក្សានីមួយៗ សូមត្រួតពិនិត្យថាតើសិស្សមានចំណេះដឹងដូចខាងក្រោមហើយឬនៅ ប្រសិនបើគ្មាននោះ សិស្សនឹងពិបាកសម្រេចបានវត្ថុបំណងមេរៀន

1. ភ្នាក់ងារបង្កជំងឺ
   ផ្សិត ប្រូទីស បាក់តេរី វីរុស
2. ប្រព័ន្ធភាពស៊ាំ
   កោសិកា T

## ជំងឺឆ្លង

### វត្ថុបំណង

ពន្យល់ពាក្យ "ជំងឺឆ្លង" និងរបៀបនៃការឆ្លងជំងឺ

### សកម្មភាព(1)

ការងារជាបុគ្គល ឬជាក្រុម សិស្សលើកឧទាហរណ៍ពីឈ្មោះជំងឺឆ្លងដែលពួកគេស្គាល់។

**"ចម្លើយរំពឹងទុក"**

ផ្តាសាយធំ ជំងឺគ្រុនចាញ់ ជំងឺអេដស៍...

សិស្សពិភាក្សាគ្នាពីមូលហេតុនៃការឆ្លងជំងឺ។

**"ចម្លើយរំពឹងទុក"**

បាក់តេរី វីរុស និងមេរោគមួយចំនួនផ្សេងទៀត។

**មេរៀនទី**

**2** **ជំងឺឆ្លង**

**ចប់មេរៀននេះ សិស្សអាច**

- ពន្យល់ពាក្យជំងឺឆ្លងនិងមូលហេតុនៃការឆ្លងជំងឺ
- បង្ហាញពីជំងឺកាមរោគ ជំងឺអេដស៍ របៀបឆ្លងនិងរបៀបមិនឆ្លងនៃជំងឺទាំងនោះ
- ពណ៌នាពីការការពារខ្លួនកុំឱ្យភ្នាក់ងារបង្ករោគជ្រៀតចូលក្នុងខ្លួនបានដោយអនុវត្តក្បួនអនាម័យក្នុងការបរិភោគនិងការរស់នៅ
- អប់រំចិត្តខ្លួនឯង និងអ្នកដទៃកុំឆាប់ពាក់ព័ន្ធជាមួយសកម្មភាពផ្លូវភេទ
- ពន្យល់ពីផលវិបាកនៃជំងឺឆ្លងនិងកាមរោគ ជាពិសេសជំងឺអេដស៍ហើយចៀសវាងការប្រព្រឹត្តិអំពើណាមួយដែលបណ្តាលឱ្យឆ្លងជំងឺ ។

តើអ្នកធ្លាប់ផឹកភេសជ្ជៈជាមួយមិត្តអ្នកដែរឬទេ ? តើអ្នកនិងមិត្តអ្នកប្រើកែវរួមគ្នាក្នុងការផឹកភេសជ្ជៈឬដូចម្តេច ? ការប្រើប្រាស់កែវ ឬចានរួមគ្នាជាវិធីមួយដែលមេរោគជាច្រើនត្រូវបានឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ។

### 1. ជំងឺឆ្លង

ជំងឺដែលឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតហៅថា **ជំងឺឆ្លង** ។ ជំងឺឆ្លងបណ្តាលមកពីភ្នាក់ងារបង្ករោគ ដូចជាវីរុស បាក់តេរី ផ្សិត និងប្រូទីស ។

**ជំងឺមួយចំនួនដែលបណ្តាលមកពីភ្នាក់ងារបង្ករោគ**

| ភ្នាក់ងារបង្ករោគ | វីរុស | បាក់តេរី | ប្រូទីស | ផ្សិត |
|---|---|---|---|---|
| ប្រភេទជំងឺ | ផ្តាសាយធំ | តេតាណូស | គ្រុនចាញ់ | ទឹកស៊ីជើង |
| | អេដស៍ | របេង | ជំងឺងងុយដេក | ស្រែង |
| | កញ្ជ្រឹល | គ្រុនពោះវៀន | រាកមូល | ជ្រាំងមាត់ |

222

### ចំណេះដឹងបន្ថែម

**"របកគំហើញនៃមេរោគ"**

គេបាននិយាយថា លោក អានតូនី វ៉ាន់ លីអុយវ៉េនហុក (Antony van Leeuwenhoek) (1632-1723) គឺជាមនុស្សដំបូងគេដែលបានស្វែងយល់ពិភពនៃអតិសុខុមប្រាណ(មេរោគ)ដោយមីក្រូទស្សន៍ធ្វើដោយដៃរបស់គាត់។លោកបានសង្កេតមើលទឹកភ្លៀង ទឹកទន្លេ ទឹកអណ្តូង ទឹកសមុទ្រ និងទឹកស្រះ។ គាត់បានរកឃើញអតិសុខុមប្រាណជាច្រើនក្នុងទឹក។ ដើម្បីធ្វើឱ្យមានការជឿជាក់ថាអតិសុខុមប្រាណជាភាវរស់ គាត់បានចាក់ទឹកខ្មេះទៅក្នុងទឹក។ គាត់អាចសង្កេតឃើញថាអតិសុខុមប្រាណមិនបានផ្លាស់ទី។ គាត់បានភ្ញាក់ផ្អើលនៅក្នុងការរកឃើញរបស់គាត់។

គាត់ក៏បានរកឃើញ នៅពេលគាត់មើលទៅលើពពុះ ដែលបានពីការដុសធ្មេញរបស់គាត់ផ្ទាល់ បន្ទាប់ពីមិនបានដុសលាងវាបីថ្ងៃ។ "ខ្ញុំបានសង្កេតឃើញភាពអស្ចារ្យយ៉ាងខ្លាំង គឺថាវាមានកូនសត្វរស់តូចៗជាច្រើន ហើយមានចលនាយ៉ាងស្អាត"។ គាត់បានបញ្ជាក់ពីចំនួនដ៏សម្បើមនៃអតិសុខុមប្រាណក្នុងពពុះនោះ។

### 1.1. រោគសញ្ញានៃជំងឺឆ្លងមួយចំនួន

ជំងឺឆ្លងមួយចំនួនដែលប្រទះឃើញញឹកញាប់ជាងគេមាន

| ជំងឺ | របៀបឆ្លង | រោគសញ្ញា |
|---|---|---|
| កញ្ជ្រឹល | ចរន្តខ្យល់ | ក្រហមលើស្បែក ឡើងកម្តៅ តឹងច្រមុះ និងឈឺបំពង់ក |
| អុតស្វាយ | ចរន្តខ្យល់ | ស្នាមកន្ទួលលើស្បែក |
| រលាកថ្លើម | ឆ្លងតាមឈាម ចំណីអាហារ ទឹក ការរួមភេទ | គ្រុនរងា ក្អួតចង្អោរ ហើមថ្លើម ស្បែកលឿង និងឈឺសន្លាក់ |
| គ្រុនស្វិតដៃជើង | ចំណីអាហារនិងទឹក | ឈឺក្បាល តឹងកញ្ចឹងក និងសាច់ដុំកម្រើកលែងរួច |
| ផ្តាសាយបក្សី | -ការប៉ះពាល់ ឬបរិភោគបក្សីឈឺ ឬងាប់<br>-ទៅកន្លែងដែលមានបក្សីឈឺ ឬងាប់<br>-មុជទឹកត្រពាំងឬស្រះដែលមានបក្សីហែលលេង | ឈឺក្បាល ឈឺសាច់ដុំ ថប់ដង្ហើម ក្តៅលើសពី 38°C (ក្រោយពីការប៉ះពាល់បក្សីឈឺ ឬងាប់ រយៈពេល 7 ថ្ងៃ) |

223

### វត្ថុបំណង (ត)

ពន្យល់ពាក្យ“ជំងឺឆ្លង” និងរបៀបនៃការឆ្លងជំងឺ។

### សកម្មភាព

សិស្សបំពេញចន្លោះក្នុងតារាងជំងឺឆ្លង រោគសញ្ញា និងរបៀបឆ្លងដោយប្រើពាក្យខាងក្រោម។ (សកម្មភាពជាបុគ្គល ឬជាក្រុម)

| | |
|---|---|
| ចរន្តខ្យល់ | ឈាម |
| ទឹក | បក្សីឈឺ |

| ជំងឺ | របៀបឆ្លង | រោគសញ្ញា |
|---|---|---|
| កញ្ជ្រឹល | ចរន្តខ្យល់ | ក្រហមលើស្បែក ឡើងកម្តៅ |
| អុតស្វាយ | (1) | ស្នាមកន្ទួលលើស្បែក |
| រលាកថ្លើម | (2) ចំណីរអាហារ ទឹក | គ្រុន ហើមថ្លើម |
| គ្រុនស្វិតដៃជើង | ចំណីអាហារ (3) | ឈឺក្បាល សាច់ដុំកម្រើកលែងរួច |
| ផ្តាសាយបក្សី | ការប៉ះពាល់ (4) | គ្រុន ឈឺសាច់ដុំ |

(1). ចរន្តខ្យល់ (2). ឈាម (3). ទឹក (4). បក្សីឈឺ

តាមរយៈសកម្មភាពទី(1) និងសកម្មភាពទី(2) ឱ្យសិស្សកំណត់និយមន័យនៃពាក្យជំងឺឆ្លង និងរៀបរាប់ពីរបៀបឆ្លងជំងឺ។

### ចំណេះដឹងបន្ថែម

**“ប្រវត្តិជំងឺ”**

ជំងឺជាច្រើនមនុស្សនាសម័យបុរេប្រវត្តិមិនដែលបានស្គាល់។ កាលពីដំបូងឡើយមនុស្សបានរកអាហាររបស់ពួកគេដោយការបរបាញ់សត្វព្រៃ ការបេះរុក្ខជាតិ និងគ្រាប់ផ្លែឈើ។ ក្រោយមកទៀត នៅពេលដែលមនុស្សចាប់ផ្តើមចូលចិត្តចិញ្ចឹមសត្វ ពួកគេចាប់ផ្តើមមានទំនាក់ទំនងជាមួយប្រភេទទាំងអស់នៃជំងឺ។ សត្វគោបានចម្លងជំងឺអុតធំ (cowpox : ជាជំងឺបង្កឡើងពីវីរុសដែលកើតនៅលើដោះសត្វគោ) មកមនុស្សធ្វើឱ្យកើតជំងឺអុតក្រហមតូចៗនៅពេលដែលមនុស្សបានទៅប៉ះពាល់វា។ ជ្រូក និងទាចម្លងជំងឺគ្រុនផ្តាសាយធំមកមនុស្ស និងសេះឆ្លងវីរុសបណ្តាលឱ្យកើតជំងឺផ្តាសាយ។ ទឹកបំពុលដោយមានកាកសំណល់សត្វបានបង្កជំងឺដូចជាជំងឺខាន់ស្លាក់ ជំងឺអាសន្នរោគ និងជំងឺក្អកមាន់។ តាមទីប្រជុំជន និងទីក្រុងបានផ្តល់នូវបរិយាកាសដ៏ល្អឥតខ្ចោះសម្រាប់សត្វកណ្តុរ ចៃ និងសត្វល្អិតចង្រៃដទៃទៀតដែលបង្កជំងឺ។

### វត្ថុបំណង

ពណ៌នាពីរបៀបការពារខ្លួនកុំឱ្យភ្នាក់ងារបង្ករោគជ្រៀតចូលក្នុងខ្លួនបានដោយអនុវត្តក្បួនអនាម័យក្នុងការបរិភោគ និងការរស់នៅ

### សកម្មភាព

សិស្សរៀបរាប់វិធីការពារពីជំងឺឆ្លង។

**"ចម្លើយរំពឹងទុក"**

លាងដៃនឹងសាប៊ូ ឬផឹកបរិភោគទឹកឆ្អិន
គ្របទឹកពាង ឬអាងនឹងគម្រប ឱ្យបានជិតល្អ
ដាក់អាហារឆៅ និងអាហារឆ្អិនដោយឡែកពីគ្នា

**1.2. វិធីការពារកុំឱ្យឆ្លងជំងឺ**

វិធីខាងក្រោមនេះជួយយើងកុំឱ្យឆ្លងមេរោគបាន :

- ត្រូវដុះសំអាតធ្មេញជាមួយច្រាស់និងថ្នាំដុសធ្មេញ រាល់ពេលយប់មុនចូលដំណេក ពេលព្រឹកក្រោយពីដំណេក និងក្រោយពេលបរិភោគអាហាររួច ។
- ត្រូវលាងសំអាតដៃជាមួយទឹកស្អាតនិងសាប៊ូ ឬផេះមុនពេលចូលដំណេក និងក្រោយពីប៉ះពាល់វត្ថុមិនស្អាត ។ ក្រោយពេលលាងសំអាត ត្រូវជូតជើងឱ្យស្អាតដោយកំណាត់ស្ងួតជាពិសេសចន្លោះម្រាមនីមួយៗ ។
- ត្រូវបោកសម្លៀកបំពាក់ និងសម្ភារៈដំណេកជាមួយសាប៊ូ រួចហាលឱ្យត្រូវពន្លឺថ្ងៃខ្លាំង ហើយអ៊ុតឱ្យស្ងួតជាទៀងទាត់ និងត្រូវផ្លាស់សម្លៀកបំពាក់ឱ្យបានញឹកញាប់ ។
- ត្រូវងូតទឹកច្រើនដង ជាពិសេសពេលអាកាសធាតុក្តៅ ។ ការងូតទឹកច្រើនដងជួយឱ្យស្បែកយើងចាកផុតពីជំងឺសើស្បែក ប៉ុន្តែមិនត្រូវងូតទឹករយៈពេលយូរទេ ដើម្បីចៀសវាងការត្រាំស្បែកដែលអាចឱ្យមេរោគជ្រៀតចូលដោយសារស្បែករីក ។
- ត្រូវលាងសំអាតមុខឱ្យស្អាតជានិច្ច ជាពិសេសនៅពេលយប់ជាមួយសាប៊ូដែលមានគុណភាពល្អត្រូវនឹងស្បែកមុខរបស់យើង ។
- ត្រូវទុកដាក់អាហារឆៅនិងឆ្អិនដាច់ដោយឡែកពីគ្នា ព្រោះក្នុងអាហារឆៅមានមេរោគដែលបង្គ្រោះថ្នាក់ ហើយឆ្លងចូលក្នុងអាហារឆ្អិនបាន ។ អាហារត្រូវចំអិនឱ្យបានឆ្អិនល្អ ដែលអាចសម្លាប់មេរោគបានទាំងអស់ ។ ម្យ៉ាងទៀតអាហារត្រូវបរិភោគភ្លាមៗកុំទុកយូរពេក ព្រោះការទុកដាក់អាហារឆ្អិនស្រាប់នៅសីតុណ្ហភាពធម្មតា លើសពី 2ម៉ោង មេរោគអាចបន្តពូជបានយ៉ាងឆាប់រហ័ស ។ ដូចនេះបើចង់ទុកបានយូរ ត្រូវរក្សាអាហារក្នុងទូរទឹកកក ទូរកម្តៅ ឬកន្លែងស្អាត ។
- ទឹកសម្រាប់បរិភោគត្រូវដាំឱ្យពុះល្អ និងរក្សាទឹកទុកប្រើក្នុងពាងដែលបានលាងសំអាត និងគ្របឱ្យបានជិតល្អ ។



រូបទី 2.1 : រក្សាទឹកទុកប្រើក្នុងពាងដែលបានលាងសំអាតនិងគ្របឱ្យបានជិតល្អ

រូបទី 2.2 : បរិភោគទឹកដាំពុះជានិច្ច

224

### ចំណេះដឹងបន្ថែម

**"ការការពារជំងឺកាលពីសម័យមុន"**

ជំងឺប៉េស្តបានផ្ទុះឡើងនៅសតវត្សទី 14 នៅពេលដែលវាត្រូវបានគេស្គាល់ថាជាជំងឺ Black Death ។ ទីក្រុងអ៊ីតាលីឃើញករណីដំបូងនៃជំងឺប៉េស្តនៅក្នុងឆ្នាំ1347 ហើយពីប្រទេសអ៊ីតាលីវាបានរីករាលដាលទៅដល់ទូទាំងប្រទេសបារាំង អាល្លឺម៉ង់ ហូឡង់ និងប្រទេសអង់គ្លេសបានសម្លាប់មនុស្សច្រើនជាងមួយភាគបួននៃចំនួនប្រជាជនមួយ។ គ្រូពេទ្យនាសម័យនោះមិនបានដឹងថាជំងឺនេះត្រូវបានបង្កឡើងដោយពួកមីក្រូសារពាង្គកាយឡើយ។ ពួកគាត់គិតថាការឆ្លងមេរោគនេះបានបង្កឡើងដោយព្រះពិរោធរបស់ព្រះជាម្ចាស់ និងបណ្តាលមកពីក្លិនស្អុយដែលហៅថាក្លិនអសោច។ ដូចរូបភាពដែលបានបង្ហាញគ្រូពេទ្យបានពាក់សំលៀកបំពាក់ស្បែកការពារ និងចំពុះចម្លែកដូចជារបាំងដែលពោរពេញទៅដោយស្មៅដែលមានក្លិនផ្អែម ហើយពួកគាត់បានដុតធូបនៅក្នុងបន្ទប់គេងរបស់អ្នកជំងឺក្នុងការព្យាយាមដើម្បីបណ្តេញជំងឺនេះចេញ។



(លក្ខណៈជំងឺប៉េស្ត)



*ជីវវិទ្យា ជំពូកទី ៤ មេរៀនទី ២*

### 1.3. ឥរិយាបថនៃការឆ្លងជំងឺ

ឥរិយាបថដែលអាចបណ្តាលឱ្យឆ្លងជំងឺមាន :

- ជំងឺមួយចំនួនដូចជាជំងឺអុតស្វាយនិងកញ្ជ្រឹលជាជំងឺអាចឆ្លងពីមនុស្សម្នាក់ទៅម្នាក់ទៀតបានតាមការប៉ះពាល់អ្នកជំងឺដោយផ្ទាល់ ។ ដូចនេះបើយើងប៉ះពាល់អ្នកជំងឺ ឬប្រើប្រាស់វត្ថុរួមជាមួយអ្នកជំងឺ មានកន្សែងជូតខ្លួន ក្រាសសិតសក់ កែវទឹក សម្លៀកបំពាក់ ... នោះយើងនឹងអាចឆ្លងមេរោគពីអ្នកជំងឺបាន ។
- ជំងឺផ្តាសាយ ហើមស្អួត របេង សុទ្ធតែឆ្លងតាមរយៈខ្យល់ដង្ហើម ។ ការដកដង្ហើមនៅក្បែរអ្នកជំងឺ អាចនាំយកមេរោគពីអ្នកជំងឺ ពិសេសនៅពេលដែលគេក្អក ឬកណ្តាស់ ។ ដូចនេះនៅពេលក្អកឬកណ្តាស់ អ្នកជំងឺគួរតែយកកន្សែងដៃទៅខ្ទប់មាត់ ឬច្រមុះកុំខាន ។
- ការបរិភោគអាហារព្រមទាំងភេសជ្ជៈមានផ្ទុកមេរោគនៅពេលមនុស្សក្អកឬកណ្តាស់លើវា កាន់វាដោយដៃកខ្វក់ មានរុយឬមេរោគ ឬសត្វដទៃទៀតស៊ី ឬក៏វារកាត់អាចកើតជំងឺបាន ជាពិសេសអាហារផ្អូមដែលបណ្តាលឱ្យកើតជំងឺរាកមួល ។

## 2. ជំងឺកាមរោគ

ជំងឺកាមរោគជាជំងឺមួយបែបដែលភាគច្រើនឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត តាមរយៈការរួមភេទជាមួយដៃគូមានជំងឺកាមរោគ ដោយមិនបានប្រើប្រាស់មធ្យោបាយបង្ការ ។

### 2.1. ព័ត៌មានទូទៅស្តីពីជំងឺកាមរោគ

- ជំងឺកាមរោគ គឺជាជំងឺដែលឆ្លងតាមការរួមភេទ ហើយកើតមានតាមផ្លូវភេទ ។ ជំងឺកាមរោគមិនមែនជាជំងឺតពូជទេ ។
- ជំងឺកាមរោគ មិនមែនសុទ្ធតែជាជំងឺដែលឆ្លងតាមការរួមភេទនោះទេ មានជំងឺខ្លះអាចកើតមានតាមផ្លូវភេទ ដែលបណ្តាលមកពីមេរោគមានស្រាប់នៅក្នុងប្រដាប់ភេទតែម្តង ហើយខ្លះទៀតឆ្លងតាមការប៉ះពាល់នឹងឈាម ។
- ជំងឺកាមរោគបណ្តាលមកពីមេរោគច្រើនប្រភេទ អាចជាពួកបាក់តេរី វីរុស បរាសិត និងពពួកផ្សិត ។
- ជំងឺកាមរោគមិនមែនជាជំងឺធ្ងន់ធ្ងរទេ ប៉ុន្តែបើមិនព្យាបាលទេនោះ ឬព្យាបាលមិនបានត្រឹមត្រូវ វានឹងបង្កឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ហើយអាចបណ្តាលឱ្យស្លាប់បាន ។
- អ្នកជំងឺកាមរោគមិនមែនសុទ្ធសឹងតែជាមនុស្សរួមភេទច្រើនពេកនោះទេ ព្រោះជំងឺកាមរោគមួយចំនួនអាចកើតឡើងដោយសារមូលហេតុផ្សេងៗទៀតក្រៅពីការរួមភេទ ។
- ជំងឺកាមរោគភាគច្រើនមិនបង្កឱ្យមានជារោគសញ្ញាទេ អាស្រ័យហេតុនេះហើយទើបយើងពិបាកនឹងដឹងថា តើនរណាម្នាក់មាន ឬគ្មានជំងឺកាមរោគឬអត់ ។

## វត្ថុបំណង

បង្ហាញពីជំងឺកាមរោគ និងពន្យល់ពីផលវិបាកនៃជំងឺកាមរោគបានត្រឹមត្រូវ

## សកម្មភាព (1)

គ្រូលើកឧទាហរណ៍ពីឈ្មោះជំងឺកាមរោគមួយចំនួនដូចជា ជំងឺស្វាយ ជំងឺប្រមេះ បន្ទាប់មកឱ្យសិស្សពិភាក្សាពីរបៀបរីករាលដាលនៃជំងឺកាមរោគ (ជំងឺឆ្លងតាមផ្លូវភេទ៖STD: Sexually Transmitted Diseases)។

**"ចម្លើយរំពឹងទុក"**

ការទំនាក់ទំនងជាមួយអ្នកដែលបានឆ្លងមេរោគ ការទាក់ទងជាមួយវត្ថុឆ្លងមេរោគ

## ចំណេះដឹងបន្ថែម

"ជំងឺផ្តាសាយកាលពីឆ្នាំ1918"

នៅនិទាឃរដូវនិងរដូវក្តៅ ទាហានអាមេរិច 1.5លាននាក់ត្រូវបានបញ្ជូនចុះកប៉ាល់ទៅអឺរ៉ុប។ ពួកគេទៅច្បាំងក្នុងសង្គ្រាមលោកលើកទី1 (1914-1918)។ ជាអកុសល ពួកគេជាច្រើនត្រូវបានឆ្លងវីរុសផ្តាសាយ។ ជាលទ្ធផល ទាហានអាមេរិចច្រើនជាងមួយពាន់នាក់មានជំងឺនៅអឺរ៉ុប។ បន្ទាប់មក ពួកគេបានចម្លងជំងឺផ្តាសាយធំភ្លាមៗទៅទាហានអង់គ្លេស អ៊ែស្បាញ បារាំង និងអាឡឺម៉ង់គ្រាន់តែតាមរយៈការដកដង្ហើមប៉ុណ្ណោះ។

ភ្លាមៗនោះជំងឺផ្តាសាយត្រូវបានឆ្លងពេញមួយទ្វីប។ ប្រជាជនរាប់លាននាក់ក្នុងប្រទេសជាច្រើននៅទ្វីបអឺរ៉ុបចាប់ផ្តើមឈឺ។ មនុស្សដែលបានឆ្លងវីរុសនេះបានធ្វើដំណើរ ហើយចម្លងទៅទ្វីបអាស៊ី អាព្រិច និងតំបន់ផ្សេងៗទៀត។ ត្រឹមចុងរដូវក្តៅ ជំងឺផ្តាសាយបានឆ្លងពាសពេញពិភពលោក។

### វត្ថុបំណង (គ)

បង្ហាញពីជំងឺកាមរោគ និងពន្យល់ពីផលវិបាកនៃជំងឺកាមរោគ

### សកម្មភាព (2)

សិស្សបំពេញក្នុងតារាងភ្នាក់ងារចម្លងជំងឺ និងរោគសញ្ញានៃជំងឺកាមរោគដោយប្រើពាក្យខាងក្រោម

ជំងឺមហារីក

ជំងឺអារ

សរីរាង្គនៃប្រដាប់បន្តពូជ

**2.2. ប្រភេទផ្សេងៗនៃជំងឺកាមរោគ**

ជំងឺកាមរោគដែលប្រទះឃើញញឹកញាប់ជាងគេមាន ជំងឺប្រមេះទឹកបាយ ប្រមេះទឹកថ្លា ជំងឺសិរមាន់ ជំងឺស្វាយ ជំងឺសង់មូ ជំងឺទាមឡា ។

**ក. ជំងឺប្រមេះទឹកបាយ**



ប្រដាប់បន្តពូជបុរស ប្រដាប់បន្តពូជនារី

*រូបទី 2.3 : ជំងឺប្រមេះទឹកបាយ*

ជំងឺប្រមេះទឹកបាយបណ្ដាលមកពីបាក់តេរីមួយប្រភេទឈ្មោះ នេសេរីយ៉ា ហ្គោណូរេ Neisseria Gonorrhoeae ។ ជំងឺនេះឆ្លងតាមរយៈការរួមភេទជាមួយដៃគូដែលមានផ្ទុកមេរោគនេះ ឬម្ដាយដែលមានជំងឺនេះចម្លងទៅឱ្យកូនក្នុងផ្ទៃ ។

ចំពោះមនុស្សប្រុស ជំងឺនេះធ្វើឱ្យពិបាកនោម នោមឈឺ មានចេញខ្ទុះពណ៌ស ឬលៃតងភាវពីបង្ហួរនោម ។ បើអ្នកជំងឺបណ្ដោយខ្លួនដោយពុំទៅទទួលការព្យាបាលទេនោះ ជំងឺនេះអាចបណ្ដាលឱ្យរលាកក្រពេញប្រូស្តាត រលាកពងស្វាស ដែលជាមូលហេតុបណ្ដាលឱ្យអារ(គ្មានកូន) ។ ចំពោះមនុស្សស្រីជំងឺនេះធ្វើឱ្យពិបាកនោម នោមឈឺ ឈឺតាមបង្ហួរនោម ប្រដាប់បន្តពូជ និងឈឺរន្ធគូថ ។ បើទុកយូរទៅអាចបណ្ដាលឱ្យរលាកប្រដាប់បន្តពូជ ហើយធ្វើឱ្យស្ត្រីនោះមិនអាចមានកូនបានឡើយ(អារ) ។ ចំណែកទារកវិញពេលកើតចេញពីផ្ទៃម្ដាយដែលមានជំងឺនេះ ខ្ទុះអាចហូរចូលភ្នែកទារកដែលធ្វើឱ្យមានការរលាកភ្នែក ។ ប្រសិនបើគ្មានការព្យាបាលទេនោះ ទារកអាចនឹងខ្វាក់ភ្នែកបាន ។ ម្យ៉ាងទៀតជំងឺប្រមេះទឹកបាយ បណ្ដាលឱ្យកើតជំងឺផ្សេងៗទៀតដូចជាជំងឺបេះដូង ជំងឺរលាកសន្លាក់ ឬជំងឺងងឹតភ្នែក ។

**ខ. ជំងឺប្រមេះទឹកថ្លា**



ប្រដាប់បន្តពូជបុរស ប្រដាប់បន្តពូជនារី

*រូបទី 2.4 : ជំងឺប្រមេះទឹកថ្លា*

ជំងឺប្រមេះទឹកថ្លាបណ្ដាលមកពីបាក់តេរី ក្លាមីឌីយ៉ាត្រាកូម៉ាទីស (Chlamydia Trachomatis) ។ ជំងឺនេះឆ្លងតាមការរួមភេទជាមួយដៃគូដែលមានផ្ទុកមេរោគនេះ ។ ចំពោះមនុស្សប្រុសជំងឺនេះធ្វើឱ្យឈឺ

226

ចាប់ឬក្រហាយពេលនោម នោមញឹក មានចេញទឹករាវថ្លាពីបង្ហួរនោម ជួនកាលក៏អាចមានហូរខ្ទុះចេញដែរ ពេលខ្លះជំងឺនេះមិនចេញជារោគសញ្ញាអ្វីគួឱ្យកត់សម្គាល់ឡើយ ។ ចំណែកមនុស្សស្រីវិញភាគច្រើនគ្មានរោគសញ្ញាអ្វីទាំងអស់នៅពេលដំបូង ប៉ុន្តែបើទុកយូរ ជំងឺនេះអាចបណ្ដាលឱ្យរលាកដល់ប្រដាប់បន្តពូជ ហើយនឹងធ្វើឱ្យស្ត្រីអារ ។

**គ. ជំងឺសិរមាន់**



ប្រដាប់បន្តពូជបុរស ប្រដាប់បន្តពូជនារី

*រូបទី 2.5 : ជំងឺសិរមាន់*

ជំងឺសិរមាន់ ជាជំងឺមួយដែលបង្កឡើងដោយវីរុស ឈ្មោះ យូមេន ប៉ាពីឡូម៉ា HUMAN PAPILLOMA ។ ជំងឺនេះឆ្លងតាមរយៈការរួមភេទជាមួយដៃគូដែលមានផ្ទុកមេរោគ ។ ចំពោះអ្នកកើតជំងឺនេះ គេកត់សម្គាល់ឃើញមានដុះសាច់ពកដែលមានទំហំប្រែប្រួល ពីតូចប៉ុនចុងចូប រហូតដល់ប៉ុនម្រាមដៃ ។ សាច់នេះមានរាងប្លែកៗខ្លះមូលខ្លះមានរាងដូចផ្កាស្ពៃ ហើយផ្ទៃខាងលើមានរាងគគ្រាត ពកជាបន្លា ។ ជំងឺសិរមាន់អាចកើតនៅគ្រប់ទីកន្លែងទាំងអស់ នៃប្រដាប់បន្តពូជរបស់បុរស ឬប្រដាប់បន្តពូជរបស់ស្ត្រី កន្លែងដែលស្ថិតជិតប្រដាប់បន្តពូជ ដូចជាស្បែកម្ដុំក្រលៀន និងជុំវិញរន្ធគូថជាដើម ។ បើទុកយូរទៅ ដុំពកនោះអាចរីករាលដាលកាន់តែធំឡើងៗ ។ ក្រៅពីនេះជំងឺសិរមាន់អាចបង្កឱ្យមានជំងឺមហារីក ជាពិសេសជំងឺមហារីកប្រដាប់បន្តពូជ ។ ដូចនេះការសំខាន់គឺត្រូវព្យាបាលជំងឺនេះ ដើម្បីកុំឱ្យចម្លងទៅមនុស្សដទៃ តាមរយៈការរួមភេទនិងចម្លងទៅទារកទើបកើតចេញពីផ្ទៃម្ដាយដែលមានជំងឺនេះ ។

### លទ្ធផលរំពឹងទុក

| ជំងឺ | ភ្នាក់ងារចម្លងជំងឺ | រោគសញ្ញា | លទ្ធផល |
|---|---|---|---|
| ជំងឺប្រមេះទឹកបាយ | បាក់តេរីនៃសេរីយ៉ា ហ្គោណូរេ (Neisseria *gonorrhoeae*) | អ្នកជំងឺពិបាកនោម និងពេលនោមមានការឈឺចាប់ | (1) |
| ជំងឺប្រមេះទឹកថ្លា | បាក់តេរី ក្លាមីឌីយ៉ាត្រាកូម៉ាទីស (*Chlamydia trachomatis*) | អ្នកជំងឺនោមញឹកញាប់ និងមានចេញទឹករាវថ្លាពី (2) | រលាកប្រដាប់បន្តពូជ និងជំងឺអារ |
| ជំងឺសិរមាន់ | វីរុស យូមេន ប៉ាពីឡូម៉ា (*Human papilloma*) | អ្នកជំងឺមានដុំសាច់ដុះដែលមានទំហំប្រែប្រួលពីតូចប៉ុនចុងចូប រហូតដល់ធំប៉ុនម្រាមដៃ។ | (3) |

(1). ជំងឺអារ (2). សរីរាង្គនៃប្រដាប់បន្តពូជ (3). ជំងឺមហារីក

### ឃ. ជំងឺស្វាយ



ប្រដាប់បន្តពូជបុរស ប្រដាប់បន្តពូជនារី

*រូបទី 2.6 : ជំងឺស្វាយ*

ជំងឺស្វាយបណ្តាលមកពីបាក់តេរី ត្រេប៉ូណេម៉ា ប៉ាលីដូម (TREPONEMA PALLIDUM) ឆ្លងតាមរយៈការរួមភេទជាមួយដៃគូដែលមានផ្ទុកមេរោគនេះ និងតាមរយៈម្តាយមានជំងឺឆ្លង ហើយចម្លងទៅឱ្យកូន ។ ដំណាក់កាលដំបូង គេសង្កេតឃើញអ្នកជំងឺមានដំបៅនៅលើប្រដាប់បន្តពូជ និងនៅកន្លែងដទៃទៀតដូចជា ដំបៅរលួយលើម្រាមដៃម្រាមជើងឬកន្ទួលក្រហមលើដងខ្លួន និងអវយវៈទាំងមូល ។ ដំបៅនេះមិនបង្កឱ្យមានការឈឺចាប់ទេ ហើយអាចជាសះស្បើយដោយឯកឯង ។

បើគ្មានការព្យាបាលទេនោះ មេរោគស្វាយនឹងបន្តរាលដាលហើយធ្វើឱ្យខូចសរីរាង្គសំខាន់ៗរបស់សារពាង្គកាយ ដូចជាបេះដូង សរសៃឈាម ខួរក្បាល ... ហើយអាចបណ្តាលឱ្យស្លាប់ទៀតផង ។ ចំណែកទារកដែលឆ្លងមេរោគនេះពីម្តាយអាចស្លាប់ តែជួនកាលបើមានទារកខ្លះកើតមក ទារកនោះនឹងឆែបមាត់ ក្រហាតច្រមុះ ថ្លង់ ខ្វាក់ភ្នែកក៏មាន ហើយក្នុងករណីខ្លះទៀតទារកមានឆ្អឹងខ្នងមិនធម្មតា ឬក៏ដុះធ្មេញខុសធម្មតា ។ នៅដំណាក់កាលចុងក្រោយ ជំងឺនេះអាចបណ្តាលឱ្យសន្លាក់មានទ្រង់ទ្រាយខុសធម្មតា សាច់ដុំស្វិតមិនអាចកម្រើកបាន ឬនាំឱ្យឆ្កួតវង្វេង ។

### ង. ជំងឺសង់មូ

ជំងឺសង់មូបណ្តាលមកពីបាក់តេរីឈ្មោះអេម៉ូភីល៉ុស ឌុយក្រេ (HAEMOPHILUS DUCREY) ហើយឆ្លងតាមរយៈការរួមភេទជាមួយដៃគូដែលមានផ្ទុកមេរោគនេះ ។

បីទៅប្រាំថ្ងៃក្រោយមេរោគជ្រៀតចូល គេប្រទះឃើញអ្នកកើតជំងឺមានពងតូច ជួនមានទឹកថ្លា ជួនមានខ្ទុះនៅខាងក្នុងលេចចេញត្រង់ចំណុចដែលមេរោគជ្រៀតចូល ដូចជាប្រដាប់ភេទ ។ ពងទឹកតូចៗទាំងនោះបែកក្នុងរយៈពេលខ្លី ហើយបង្កើតជាដំបៅ ។ ដំបៅនោះមានសភាពទន់ តែឈឺខ្លាំងណាស់និងអាចចេញឈាមយ៉ាងងាយ ។ ដំបៅនេះអាចជាដោយឯកឯង ប៉ុន្តែបន្ទាប់មកលេចកូនកណ្តុរនៅត្រង់ក្រលៀន ហើម ហើយដរជាអាប់សែ ។ នៅពេលអាប់សែបែក វានឹងរីកកាន់តែធំឡើងៗ ។

**វត្ថុបំណង(ត)**

បង្ហាញពីជំងឺកាមរោគ និងពន្យល់ពីផលវិបាកនៃជំងឺកាមរោគបាន

**សកម្មភាព (3)**

សិស្សបំពេញចន្លោះក្នុងតារាងភ្នាក់ងារជំងឺ និងរោគសញ្ញានៃជំងឺឆ្លងតាមផ្លូវភេទដោយប្រើពាក្យខាងក្រោម

| កូនកណ្តុរ | បេះដូង |
|---|---|

**លទ្ធផលរំពឹងទុក**

| ជំងឺ | ភ្នាក់ងារចម្លងជំងឺ | រោគសញ្ញា | លទ្ធផល |
|---|---|---|---|
| ជំងឺស្វាយ | បាក់តេរី ត្រេប៉ូណេម៉ា (*Treponema pallidum*) | អ្នកជំងឺមានដំបៅនៅលើប្រដាប់បន្តពូជ និងដំបៅរលួយលើម្រាមដៃ ឬម្រាមជើង ឬកន្ទួលក្រហមលើដងខ្លួន | បាក់តេរីនេះនឹងរីករាលដាល និងធ្វើឱ្យខូចសរីរាង្គដូចជា (1) សរសៃឈាម ខួរក្បាល និងបណ្តាលឱ្យស្លាប់។ |
| ជំងឺសង់មូ | បាក់តេរី អេម៉ូភីល៉ុស ឌុយក្រេ (*Haemophilus ducrey*) | ពងទឹកតូចៗបែកក្នុងរយៈពេលខ្លី ហើយវិវត្តទៅជាដំបៅ។ | ហើម (2) ហើយក្លាយជាអាប់សែ។ |

(1). បេះដូង (2). កូនកណ្តុរ

***សម្គាល់៖** តារាងក្នុងទំព័រទី(8) និងតារាងក្នុងទំព័រទី(9) អាចដាក់បន្តគ្នាតែមួយបាន ព្រោះសកម្មភាព(2) និងសកម្មភាព(3) ធ្វើក្នុងម៉ោងតែមួយ។*

**វត្ថុបំណង**

បង្ហាញពីជំងឺកាមរោគ និងពន្យល់ពីផលវិបាកនៃជំងឺកាមរោគ

**សកម្មភាព (4)**

សិស្សពិភាក្សាពីវិធានការការពារ និងការព្យាបាលជំងឺកាមរោគ។

**"ចម្លើយរំពឹងទុក"**

អ្នកគួរតែទៅជួបគ្រូពេទ្យឯកទេសដែលមានការវិនិច្ឆ័យ និងព្យាបាលត្រឹមត្រូវ។

អ្នកគួរតែអនុវត្តតាមការណែនាំក្នុងការព្យាបាលរបស់គ្រូពេទ្យ។

អ្នកគួរតែប្រើស្រោមអនាម័យនៅពេលរួមភេទ។

អ្នកមិនគួររួមភេទមុនពេលជាសះស្បើយពីជំងឺ។

**2.3. ការព្យាបាលជំងឺកាមរោគ**

ជំងឺកាមរោគភាគច្រើនទាមទារការព្យាបាលធម្មតា ប្រសិនបើយើងបានទទួលការព្យាបាលតាំងពីដំបូង ហើយអាចជាបានយ៉ាងរហ័សដោយគ្មានបន្សល់នូវបញ្ហាធំដុំឡើយ ។ ប៉ុន្តែអ្នកជំងឺមិនបានទទួលការព្យាបាលទាល់តែសោះ វាអាចនឹងមានផលវិបាកធ្ងន់ធ្ងរដូចជាបណ្តាលឱ្យមានកូនក្រៅស្បូន គ្មានកូន បង្ហូរនោមរួមតូច កូនស្លាប់ក្នុងពោះ ឬកើតមិនធម្មតា(ចំពោះម្តាយកំពុងកើតជំងឺស្វាយ) កូនកើតមកខ្វាក់ភ្នែកពីកំណើត(នៅពេលម្តាយមានជំងឺប្រមេះទឹកបាយ) ។

ធ្ងន់ធ្ងរជាងនេះទៅទៀត ការរលាកឬដំបៅនៅប្រដាប់បន្តពូជ ដែលបណ្តាលមកពីជំងឺកាមរោគជួយដល់ការជ្រៀតចូលនៃមេរោគអេដស៍ ។ ប្រសិនបើឆ្លងមេរោគអេដស៍ហើយ គ្មានថ្នាំព្យាបាលឱ្យជាសះស្បើយឡើយ គឺមានតែសេចក្តីស្លាប់ ។ ដោយឡែក យើងអាចចម្លងមេរោគនេះទៅអ្នកដទៃដោយមិនដឹងខ្លួន ព្រោះនៅពេលឆ្លងមេរោគអេដស៍ចូលទៅក្នុងខ្លួន ពុំមានរោគសញ្ញាអ្វីទាំងអស់ ។

ដូចនេះយើងមិនត្រូវបណ្តែតបណ្តោយឱ្យជំងឺដែលអាចព្យាបាលជា ប្រែក្លាយទៅជាជំងឺដែលមិនអាចព្យាបាលជានោះទេ ។

228

**ចំណេះដឹងបន្ថែម**

ប្រសិនបើ អ្នកបារម្ភអំពីខ្លួនរបស់អ្នក អ្នកគួរតែទៅមន្ទីរពេទ្យឱ្យបានលឿនតាមដែលអាចធ្វើបាន ឬអ្នកគួរតែធ្វើតេស្តឈាមពិនិត្យមើលពីជំងឺឆ្លងតាមផ្លូវភេទ។

ប្រសិនបើ អ្នកទៅមន្ទីរពេទ្យយឺតពេល អ្នកនឹងអាចទៅជាអារនៅពេលអនាគត ឬអ្នកនឹងមានគ្រោះថ្នាក់ធ្ងន់ធ្ងរក្នុងរាងកាយរបស់អ្នក។

ប្រសិនបើ អ្នកមិនអាចទៅមន្ទីរពេទ្យតែម្នាក់ឯង អ្នកគួរតែពិភាក្សាជាមួយគ្រូ ឬឪពុកម្តាយរបស់អ្នកឱ្យលឿនបំផុត។

### 3. ជំងឺអេដស៍ AIDS

រហូតមកដល់បច្ចុប្បន្ននេះ គ្មានប្រទេសណាមួយដែលចៀសផុតពីការឆ្លងរាលដាលនៃមេរោគអេដស៍ឡើយ គ្រាន់តែកម្រិតនៃការរាលដាលមានទំហំខុសគ្នាប៉ុណ្ណោះ។ ប្រទេសដែលរងគ្រោះថ្នាក់ដោយការរាលដាលខ្លាំងជាងគេគឺ ប្រទេសក្រីក្រ។ ដូចនេះដើម្បីចូលរួមទប់ស្កាត់នូវការរាលដាលនៃមេរោគអេដស៍ យើងត្រូវមានចំណេះដឹងមូលដ្ឋានពីមេរោគអេដស៍និងជំងឺអេដស៍។

#### 3.1. និយមន័យនៃជំងឺអេដស៍

AIDS ជាអក្សរកាត់នៃភាសាអង់គ្លេស

A : Acquired កើតក្រោយពីការឆ្លង

I : Immune ភាពស៊ាំ

D : Deficiency ចុះខ្សោយ

S : Syndrome ចង្កោមរោគសញ្ញា

SIDA ជាអក្សរកាត់នៃភាសាបារាំង: Syndrome d'Immuno déficience Acquise

ជំងឺអេដស៍ AIDS (Acquised Immune Deficiency Syndrome) មានឥទ្ធិពលទៅលើប្រព័ន្ធស៊ាំ។ ដូចនេះជំងឺអេដស៍មានន័យថា ប្រជុំរោគសញ្ញាដែលកើតឡើងក្រោយពេលប្រព័ន្ធស៊ាំចុះខ្សោយ។

មូលហេតុបង្កឱ្យមានជំងឺអេដស៍ គឺជាវីរុស HIV (Human Immuno deficiency virus ) ។ HIV ជាវីរុសដែលធ្វើឱ្យប្រព័ន្ធស៊ាំចុះខ្សោយ។

229

**វត្ថុបំណង**

ពន្យល់ពីរបៀបឆ្លង និងរបៀបមិនឆ្លងនៃជំងឺអេដស៍

**សកម្មភាព**

សិស្សពិភាក្សាពីការយល់ដឹងនៃអំពីជំងឺអេដស៍ទៅវិញទៅមក។

**"ចម្លើយរំពឹងទុក"**

ជំងឺដែលបណ្តាលឱ្យស្លាប់ មិនអាចព្យាបាលបាន ជំងឺអេដស៍ទាក់ទងនឹងការរួមភេទភេទដូចគ្នា។

**ចំណេះដឹងបន្ថែម**

**"ប្រវត្តិជំងឺអេដស៍ និងយន្តការ"**

មុនឆ្នាំ1981 ជំងឺអេដស៍ ឬរោគសញ្ញាចុះខ្សោយប្រព័ន្ធភាពស៊ាំមិនត្រូវបានដឹងឡើយ។ នៅចន្លោះឆ្នាំ1981 និងឆ្នាំ2000 ប្រជាជនអាមេរិចជាង 448,000នាក់បានស្លាប់ដោយសារជំងឺអេដស៍។ បន្ទាប់ពីពេលនោះមក ចំនួនសរុបនៃប្រជាជនមានផ្ទុក វីរុស HIV នៅសហរដ្ឋអាមេរិចបានកើនឡើងច្រើនជាង850,000នាក់។ អេដស៍ជាជំងឺដែលបណ្តាលមកពីវីរុស HIV ឬវីរុសដែលធ្វើឱ្យប្រព័ន្ធភាពស៊ាំមនុស្សចុះខ្សោយ។

អ្នកវិទ្យាសាស្ត្រជាច្រើនបានគិតថាវីរុស HIV វិវត្តពីវីរុសមួយប្រភេ ទដែលស្រដៀងគ្នាទៅនឹងវីរុសមួយ ដែលឆ្លងពីព្រីម៉ាតនៅក្នុងប្រទេសអាហ្វ្រិក។ ជាធម្មតា វីរុស HIV ទន្ទ្រាន T ជំនួយដែលបានចាប់ផ្តើមបង្កើត HIV យ៉ាងឆាប់រហ័សបន្ទាប់ពីការឆ្លងមេរោគ។ ដោយសារតែកោសិកាT ជំនួយស្លាប់ ប្រព័ន្ធភាពស៊ាំក៏ចុះខ្សោយបន្តិចម្តងៗ ក្លាយទៅជាបាក់ងើបលែងរួចដោយសារភ្នាក់ងារបង្កជំងឺដែលជាធម្មតាប្រព័ន្ធភាពស៊ាំមាននាទីការពារ និងបំផ្លាញភ្នាក់ងារបង្កជំងឺ។ សារពាង្គកាយងាយទទួលឥទ្ធិពលជំងឺផ្សេងៗដែលហៅថាជំងឺឆ្លៀតឱកាស ឬជំងឺឱកាសនិយម ដែលជាទូទៅបណ្តាលឱ្យមានជំងឺចំពោះតែមនុស្សដែលមានប្រព័ន្ធភាពស៊ាំចុះខ្សោយប៉ុណ្ណោះ។

## វត្ថុបំណង

ពន្យល់ពីរបៀបឆ្លង និងរបៀបមិនឆ្លងនៃជំងឺអេដស៍

## សកម្មភាព

សិស្សសង្ខេបពីការវិវត្តនៃជំងឺអេដស៍ "លទ្ធផលរំពឹងទុក"

- ✦ ដំណាក់កាលចំហ
  - ឆ្លងវីរុសអេដស៍ និងចម្លងទៅអ្នកដទៃ
  - គ្មានរោគសញ្ញា
- ✦ ដំណាក់កាលតេស្តឈាមវិជ្ជមាន
  - តេស្តឈាមវិជ្ជមាន
  - មានរោគសញ្ញាតិចតួច
- ✦ ដំណាក់កាលជំងឺអេដស៍
  - រោគសញ្ញាធ្ងន់ធ្ងរ

**3.2. ការវិវត្តរបស់ជំងឺអេដស៍**

តើមានអ្វីកើតឡើងក្រោយពីមេរោគអេដស៍ចូលក្នុងខ្លួន ? មានដំណាក់កាលបីសំខាន់ មុននឹងវិវត្តទៅដល់ជំងឺអេដស៍ ។ ដំណាក់កាលទាំងនោះគឺ

- ដំណាក់កាលចំហ : គឺការឆ្លងដំបូង ។ អ្នកផ្ទុកមេរោគអេដស៍មួយចំនួនតូចមានរោគសញ្ញាបន្តិចបន្តួចដូចជាផ្តាសាយមិនគួរឱ្យចាប់អារម្មណ៍ ហើយអ្នកផ្ទុកមេរោគអេដស៍មួយចំនួនធំមានសុខភាពល្អជាធម្មតា ពុំមានរោគសញ្ញាអ្វីទាំងអស់ ។ នៅពេលឆ្លងមេរោគអេដស៍ភ្លាម បើអ្នកនោះធ្វើតេសឈាមគឺមិនអាចមើលឃើញទេ ដោយសារតែអ្នកនោះត្រូវស្ថិតនៅក្នុងដំណាក់កាលចំហ ។ នៅដំណាក់កាលចំហប្រព័ន្ធស៊ាំរបស់សារពាង្គកាយត្រូវការពេលមួយដែលមានរយៈពេលពី 3-6 ខែដើម្បីផលិតអង់ទីករប្រឆាំងនឹងមេរោគអេដស៍ ។
- ដំណាក់កាលតេស្តឈាមវិជ្ជមាន : ក្នុងដំណាក់កាលនេះ អ្នកផ្ទុកមេរោគអេដស៍ភាគច្រើនមានសុខភាពល្អ ។ គេពិនិត្យឃើញអ្នកផ្ទុកមេរោគអេដស៍មួយចំនួនតូចមានចេញកូនកណ្តុរនៅក្លៀក នៅក ។ ពេលនោះការធ្វើតេស្តឈាមផ្តល់លទ្ធផលវិជ្ជមាន ។
- ដំណាក់កាលជំងឺអេដស៍ : ភាគច្រើននៃអ្នកផ្ទុកមេរោគអេដស៍នឹងវិវត្តទៅរកជំងឺអេដស៍ក្នុងរយៈពេល 10 ឆ្នាំ តែទោះបីជាយ៉ាងណាក៏ដោយ រយៈពេលអតិបរិមារបស់វានៅតែមិនច្បាស់ ហើយប្រែប្រួលទៅតាមបុគ្គលម្នាក់ៗ ។ ក្នុងរយៈពេលនេះ អ្នកជំងឺទទួលការវាតត្បាតពីមេរោគឱកាសនិយមដូចជា របេង រាក មហារីក ជំងឺសើស្បែក ហើយវិវត្តទៅរកសេចក្តីស្លាប់ក្នុងរយៈពេលពីរឬបីឆ្នាំបន្ទាប់ ។

ការវិវត្តរបស់មេរោគអេដស៍




230

## ចំណេះដឹងបន្ថែម

ដំណាក់កាលចំហ ចំពោះជំងឺអេដស៍ត្រូវបានគេហៅថារយៈពេលសំងំ។ រយៈពេលសំងំមានន័យថាជាដំណាក់កាលវិវត្តនៃជំងឺឆ្លងរវាងការឆ្លងមេរោគដំបូង និងការបង្ហាញនៃរោគសញ្ញាដំបូង។

បើយោងតាមសៀវភៅពុម្ព រយៈពេលសំងំចំពោះជំងឺអេដស៍អាចមានរយៈពេលប្រហែល 10 ឆ្នាំ។

នៅក្នុងករណីជំងឺរលាកថ្លើម, រយៈពេលសំងំគឺមានប្រហែលជាកន្លះឆ្នាំ។

របៀបឆ្លងមេរោគអេដស៍ប៉ះពាល់ដល់រាងកាយ

វីរុស HIV គឺជាវីរុសមួយប្រភេទដែលគេស្គាល់ថាវាគ្រាន់តែបំផ្លាញប្រព័ន្ធភាពស៊ាំរបស់មនុស្សដោយផ្ទាល់ និងបំផ្លាញកោសិកាT។ នៅពេលដែលវាជ្រៀតចូលរាងកាយ វីរុស HIV ចូលកោសិកា T ហើយបន្តពូជនៅក្នុងកោសិកានោះ។ មនុស្សអាចឆ្លង វីរុស HIV បាន មានន័យថាថាមានមេរោគរស់នៅក្នុងកោសិកាT របស់ពួកគេ អស់រយៈពេលជាច្រើនឆ្នាំមុនពេលដែលពួកគេឈឺ។ ទីបំផុត វីរុសHIVចាប់ផ្តើមដើម្បីបំផ្លាញកោសិកា T ដែលវាបានឆ្លង វីរុស HIV។ ដោយមេរោគបំផ្លាញកោសិកា T រាងកាយបាត់បង់នូវសមត្ថភាពរបស់ខ្លួនក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺ។ មនុស្សភាគច្រើនដែលបានឆ្លងវីរុស HIV នៅទីបំផុតវិវត្តនូវរោគសញ្ញានៃជំងឺអេដស៍។

ដោយសារតែប្រព័ន្ធភាពស៊ាំរបស់ពួកគេមិនមានមុខងារត្រឹមត្រូវយូរទៅ ទីបំផុតប្រព័ន្ធភាពស៊ាំចុះខ្សោយចុងបញ្ចប់បណ្តាលឱ្យមនុស្សស្លាប់។

*ជីវវិទ្យា ជំពូកទី ៤ មេរៀនទី ២*

**3.3. បណ្តុំរោគសញ្ញាទាក់ទងនឹងដំណាក់កាលអេដស៍**

មួយភាគបីនៃអ្នកផ្ទុកមេរោគអេដស៍នឹងវិវត្តទៅរកជំងឺអេដស៍ ក្រោយពីបានផ្ទុកមេរោគអេដស៍អស់រយៈពេលប្រហែល 7ឆ្នាំ ។ ជំងឺអេដស៍លេចឡើងនៅពេលដែលប្រព័ន្ធស៊ាំត្រូវបានខូចខាតធ្ងន់ធ្ងរ ។ ជំងឺអេដស៍ស្តែងឡើងដោយចង្កោមរោគសញ្ញាដែលទាក់ទងនឹងជំងឺឱកាសនិយម ជំងឺមហារីក និងចង្កោមរោគសញ្ញាផ្សេងៗទៀត(សរសៃប្រសាទនិងស្រកទម្ងន់) ។

**ក. ជំងឺឱកាសនិយម**

- **និយមន័យ** : នៅជុំវិញខ្លួនយើងមានវីរុស បាក់តេរី និងបរាសិត ដែលជាទូទៅវាមិនបង្កឱ្យមានជំងឺទេដោយសារប្រព័ន្ធស៊ាំនៃសារពាង្គកាយរបស់យើងរឹងមាំ ។ នៅពេលដែលប្រព័ន្ធស៊ាំនៃសារពាង្គកាយចុះខ្សោយ មេរោគឆ្លៀតឱកាសចូលទៅក្នុងខ្លួន ដើម្បីបង្កជំងឺដែលគេឱ្យឈ្មោះថាជាជំងឺឱកាសនិយម ។ ជំងឺឆ្លងទាំងនេះធ្ងន់ធ្ងរណាស់ ដោយសារសារពាង្គកាយមិនអាចបង្ការខ្លួនឯងបាន ទោះបីជាគ្មានថ្នាំព្យាបាល ឬជួនកាលមានការព្យាបាលក៏ដោយ ។
- **រោគសញ្ញា** : ប្រែប្រួលទៅតាមមេរោគនិងសរីរាង្គដែលប៉ះពាល់ ។ សរីរាង្គដែលងាយប៉ះពាល់ជាងគេគឺ ក្រពះ ពោះវៀនមានជំងឺរ៉ាំរ៉ៃគ្មានមូលហេតុមានរយៈពេលច្រើនជាងមួយខែ ពិបាកក្នុងការបរិភោគ ដោយសាររលាកក្រពះ ជំងឺពោះវៀនធ្ងន់ធ្ងរ និងរាករ៉ាំរ៉ៃ ។ ខួរក្បាលមានជំងឺរលាកស្រោមខួរ រោគសញ្ញាសរសៃប្រសាទ ស្រវាំងភ្នែក ខ្វិន ស្បែកមានជំងឺ ដំបៅលើស្បែក ។ ស្ថានភាពទូទៅ អ្នកជំងឺស្រកទម្ងន់ អស់កម្លាំងល្ហិតល្ហៃ ដោយអមជាមួយជំងឺផ្សេងៗ ។

**ខ. ជំងឺមហារីកមួយចំនួន**

- **ជំងឺមហារីកសរសៃឈាម** : ជាជំងឺមហារីកដែលជួបញឹកញាប់បំផុតរហូតដល់ 35% នៃអ្នកកើតជំងឺអេដស៍ ។ ជំងឺនេះគឺជាដុំពកៗ ឬក៏ជាបន្ទះមានពណ៌ខៀវ ឬពណ៌ត្នោតនៅលើស្បែក ។ គេបានរកឃើញដុំពកទាំងនេះមិនត្រឹមតែនៅលើស្បែកទេ តែមាននៅលើកូនកណ្តុរ សួត និងសរីរាង្គទាំងអស់ក្នុងសារពាង្គកាយ ។
- **ឡាំផូមា (Lymphomas)** : ឡាំផូម៉ាជាដុំពកនៅតាមកូនកណ្តុរ ។ គ្រោះថ្នាក់នៃឡាំផូម៉ានេះមានប្រហែល 100ដងនៅលើអ្នកជំងឺអេដស៍ជាងនៅលើមនុស្សធម្មតា ។
- **ជំងឺផ្សេងៗទៀត** : មេរោគហ៊ីវអាចប៉ះពាល់ដោយផ្ទាល់លើប្រព័ន្ធសរសៃប្រសាទកណ្តាលបណ្តាលឱ្យកើតជំងឺខូចខួរក្បាល ។ បណ្តុំរោគសញ្ញាដែលបណ្តាលឱ្យស្រកទម្ងន់ ត្រូវបានគេហៅថា ជំងឺដែលធ្វើឱ្យស្រកទម្ងន់ ។

231

## វត្ថុបំណង (ត)

ពន្យល់ពីរបៀបឆ្លង និងរបៀបមិនឆ្លងនៃជំងឺអេដស៍

## សកម្មភាព

សិស្សសង្ខេបពីរោគសញ្ញាទាក់ទងនឹងជំងឺអេដស៍។

**"លទ្ធផលរំពឹងទុក"**

- ជំងឺឆ្លៀតឱកាស ឬជំងឺឱកាសនិយម
- ខ្លះកើតជំងឺមហារីក និងជំងឺផ្សេងៗ

## ចំណេះដឹងបន្ថែម
**"ទាក់ទងនឹងការឆ្លងជំងឺអេដស៍"**

វីរុសHIV បណ្តាលឱ្យកើតជំងឺមហារីក និងការឆ្លងជំងឺ ដោយភ្នាក់ងារបង្កជំងឺឆ្លៀតឱកាស ដែលមានជាទូទៅ ចំពោះបុគ្គល មានប្រព័ន្ធភាពស៊ាំល្អ។

ការឆ្លងមេរោគ និងជំងឺមហារីកមានទំនាក់ទំនងជាមួយនឹងជំងឺអេដស៍រួមមាន ជំងឺមហារីកដុំសាច់នៃកាប៉ូស៊ី (Kaposi) ជំងឺរលាកសួតភ្នឺម៉ូស៊ីស្ទីស ការីនី(*Pneumocystis carinii*) ជំងឺកាឌីយ៉ាស៊ីស(candidiasis) និងជំងឺផ្សេងៗទៀត។ ជំងឺមហារីកដុំសាច់នៃកាប៉ូស៊ីគឺជាមហារីកស្បែក និងស្រទាប់ភ្នាសជាលិកាដែលជាញឹកញាប់រាលដាលតាមរយៈសរីរាង្គផ្សេងទៀត។ ជាទូទៅ អ្នកជំងឺអេដស៍តែងតែមានជំងឺរលាកសួត។ ជំងឺកាឌីយ៉ាស៊ីសត្រូវបានគេស្គាល់ថា ជាជំងឺពងបែក ដែលជាការឆ្លងមេរោគផ្សិតធ្វើឱ្យមានពណ៌សដេរដាសពាសពេញក្នុងមាត់ អណ្តាត និងសរីរាង្គផ្សេងទៀតនៃប្រដាប់រំលាយអាហារ។ ភ្នាក់ងារបង្កជំងឺឆ្លៀតឱកាសមានដូចជា វីរុសស៊ីតូមេកាឡូ (cytomegalovirus) ដែលផលិតតំណបរលាករ៉េទីន ពោះវៀនធំ និងក្រពេញអាដ្រេណាល់ ហើយជំងឺរបេង និងការឆ្លងជំងឺសាលម៉ូនេឡា(*Salmonella*) ជំងឺទាំងពីរបណ្តាលមកពីបាក់តេរី។

## វត្ថុបំណង (ត)

ពន្យល់ពីរបៀបឆ្លង និងរបៀបមិនឆ្លងនៃជំងឺអេដស៍

## សកម្មភាព

សិស្សពិភាក្សាពីរបៀបឆ្លង និងពីរបៀបទាក់ទងជាមួយអ្នកជំងឺអេដស៍ដោយសុវត្ថិភាព តាមរយៈការជ្រើសរើសរូបភាពក្នុងសៀវភៅពុម្ព ទំព័រទី 232និងទំព័រ 233។

**"ចម្លើយរំពឹងទុក"**

ការចាប់ដៃគឺមិនឆ្លង....។

ការសាក់ស្បែកគឺឆ្លង...។

### 3.5. របៀបឆ្លងនិងរបៀបមិនឆ្លងនៃមេរោគអេដស៍

**ក. របៀបឆ្លង**

មេរោគអេដស៍អាចឆ្លងតាមរបៀបបីសំខាន់ៗគឺ



អេដស៍ឆ្លងតាមការរួមភេទ

- តាមរយៈការរួមភេទ : រាល់ការរួមភេទទាំងអស់ជាមួយអ្នកផ្ទុកមេរោគអេដស៍ អាចឆ្លងមេរោគទៅឱ្យដៃគូ ព្រោះក្នុងពេលរួមភេទ វីរុសអេដស៍អាចឆ្លងតាមរយៈទឹកកាមបុរសទៅស្ត្រី ឬក៏អាចឆ្លងតាមរយៈទឹករំអិលនៃប្រដាប់បន្តពូជស្ត្រីទៅបុរសវិញ ។
- តាមការប៉ះពាល់ឈាម : ជំងឺអេដស៍អាចឆ្លងតាមរយៈសារធាតុរាវក្នុងសារពាង្គកាយ ជាពិសេសឈាម ទឹករងៃ ។ យើងអាចឆ្លងជំងឺអេដស៍បាន ប្រសិនបើឈាមរបស់អ្នកជំងឺអេដស៍ចូលក្នុងខ្លួនរបស់យើង ។
- ប្រើម្ជុលឬសឺរ៉ាំងរួមគ្នា : តាមរយៈការសាក់ស្បែក ចោះត្រចៀក (ការប្រើប្រាស់ប្រដាប់ចាក់ទម្លុះស្បែក) ការប្រើប្រាស់ច្រាសដុសធ្មេញជាមួយអ្នកជំងឺ និងតាមរយៈការមុតឬរបួសស្បែកផ្សេងៗទៀត ។ ការបញ្ចូលឈាមអ្នកជំងឺអេដស៍ក្នុងខ្លួនយើង ។



រូបទី 2.7 : សាក់ស្បែក



រូបទី 2.8 : ប្រើម្ជុលសឺរ៉ាំងរួមគ្នា



រូបទី 2.9 : ការបញ្ចូលឈាម

- ពីម្ដាយទៅទារក : ជាការចម្លងពីមាតាដែលមានផ្ទុកមេរោគអេដស៍ទៅឱ្យទារករបស់ខ្លួន ហើយការចម្លងនេះអាចធ្វើឡើងតាំងពីទារកនៅក្នុងផ្ទៃ នៅពេលកើត(ពេលប្រសូត្រ)និងនៅពេលបំបៅកូនដោយទឹកដោះ ។



រូបទី 2.10 : ទារកនៅក្នុងផ្ទៃ



រូបទី 2.11 : នៅពេលកើត



រូបទី 2.12 : នៅពេលបំបៅដោះកូន

| ការឆ្លងនៃជំងឺអេដស៍ | ការមិនឆ្លងនៃជំងឺអេដស៍ |
|---|---|
| ការរួមភេទ | ការចាប់ដៃ |
| ការប្រើម្ជុល ឬសឺរ៉ាំងរួមគ្នា | ការឱបគ្នា |
| ការប៉ះពាល់ឈាម | ការប្រើប្រាស់កៅអី បង្គន់មួយរួមគ្នា |
| ការបំបៅទឹកដោះ | ការលេងកីឡា |

## ខ. របៀបមិនឆ្លង




*រូបទី 2.13 : សកម្មភាពខាងលើនេះមិនអាចឱ្យអ្នកឆ្លងមេរោគអេដស៍ទេ*

មេរោគអេដស៍មិនអាចឆ្លងតាមរយៈខ្យល់ អាហារ ឬទឹកទេ ។ មេរោគនេះមិនអាចរស់នៅក្រៅខ្លួនបានយូរឡើយ ។ សារធាតុរាវដែលមានកំហាប់មេរោគខ្ពស់នោះមាន ឈាម ទឹកកាមបុរស ទឹករំអិលនៃប្រដាប់បន្តពូជនារី ទឹករងៃ ។ ជារួម រាល់ទំនាក់ទំនងនិងការប្រាស្រ័យទាក់ទងជាសាធារណៈនៅក្នុង ការរៀនសូត្រ បំពេញការងារ នៅតាមគ្រួសារ និងសង្គមទាំងអស់ដូចជា ក្អក កណ្តាស់ ចាប់ដៃ លេងជាមួយគ្នា បរិភោគបាយរួមគ្នា ប្រើបង្គន់រួមគ្នា ការថែទាំអ្នកជំងឺអេដស៍ គឺមិននាំឱ្យមានការចម្លងមេរោគអេដស៍ទេ ។ មូសនិងសត្វដែលចិញ្ចឹមក្នុងផ្ទះ គឺមិនអាចចម្លងមេរោគអេដស៍បានឡើយ ។

### វត្ថុបំណង (ត)

ពន្យល់ពីរបៀបឆ្លង និងរបៀបមិនឆ្លងនៃជំងឺអេដស៍

### សកម្មភាព

ផ្អែកលើក្រាភិចខាងក្រោមសិស្សឆ្លើយនឹងសំណួរ។

**សំណួរទី1**

តើចំនួនអ្នកជំងឺអេដស៍បានប្រែប្រួលយ៉ាងដូចម្តេចចាប់តាំងពីឆ្នាំ1996?

**សំណួរទី2**

តើចំនួនប្រជាជនអាមេរិចដែលឆ្លងវីរុស HIVទំនងជាច្រើនជាង ឬតិចជាងអ្នកជំងឺអេដស៍?

**សំណួរទី3**

ក្រាភិចនេះបង្ហាញថាចំនួននៃករណី ជំងឺអេដស៍ថ្មីដែលបានរាយការណ៍ជារៀងរាល់ឆ្នាំបានថយចុះចាប់តាំងពីឆ្នាំ 1996។ ចូរលើកហេតុផលសមស្របមួយសម្រាប់ការថយចុះនេះ។




AIDS cases in USA

ករណីជំងឺអេដស៍ នៅសហរដ្ឋអាមេរិច

**វត្ថុបំណង (ត)**

ពន្យល់ពីរបៀបឆ្លង និងរបៀបមិនឆ្លងនៃជំងឺអេដស៍

**សកម្មភាព**

ចម្លើយនៃក្រាភិច

**សំណួរទី1**

ករណីត្រូតគ្នាបានកើនឡើង ប៉ុន្តែករណីជំងឺអេដស៍បានថយចុះ។

**សំណួរទី2**

ប្រជាជនអាមេរិចដែលឆ្លងវីរុសHIV មានចំនួនច្រើនជាងអ្នកជំងឺអេដស៍។ អ្នកបានឆ្លង វីរុស HIV ទាំងអស់មិនបានវិវត្តទៅជាជំងឺអេដស៍ទាំងអស់ទេ។

**សំណួរទី 3**

ថ្នាំថ្មីពន្យារពេលជំងឺអេដស៍ចំពោះអ្នកដែលបានឆ្លងវីរុស HIV។

**3.6. ការបង្ការមេរោគអេដស៍និងកាមរោគ**

យើងអាចការពារខ្លួនយើង ពីការឆ្លងមេរោគអេដស៍ និងកាមរោគ ដោយគ្រាន់តែជ្រើសរើសផ្លូវដែលមានសុវត្ថិភាពខ្ពស់ក្នុងការប្រព្រឹត្តិរបស់យើង ។ មានតែមធ្យោបាយទាំងនេះទេ ដែលអាចកាត់បន្ថយគ្រោះថ្នាក់នៃការឆ្លង ។ មធ្យោបាយសំខាន់ៗមាន :

- យុវវ័យកុំឆាប់ប្រឡូកក្នុងការរួមភេទ
- ស្មោះត្រង់មួយទល់នឹងមួយ
- ប្រើស្រោមអនាម័យឱ្យបានត្រឹមត្រូវគ្រប់ពេលរួមភេទជាមួយដៃគូក្រៅ
- ចៀសវាងប្រើម្ជុល ឬសឺរ៉ាំងនិងសម្ភារៈទម្លុះស្បែកផ្សេងទៀតរួមគ្នា ។

**3.7. ផលប៉ះពាល់នៃជំងឺអេដស៍**

ជំងឺអេដស៍បានផ្តល់នូវផលប៉ះពាល់ជាប្រព័ន្ធទៅលើបុគ្គល គ្រួសារ និងសង្គមជាតិទាំងមូលយ៉ាងធ្ងន់ធ្ងរដូចជា

- អេដស៍នាំមកនូវជំងឺរ៉ាំរ៉ៃ ដែលទាមទារថវិកាព្យាបាលយ៉ាងច្រើន ។
- អេដស៍នាំមកនូវការស្លាប់ប្តី ប្រពន្ធ ហើយការបន្សល់ទុកនូវក្មេងកំព្រាដែលជាបន្ទុកយ៉ាងធ្ងន់ធ្ងរដល់សង្គម ។
- អេដស៍បំផ្លាញទ្រព្យសម្បត្តិ គ្រួសារហិនហោច និងជំពាក់បំណុលគេថែមទៀតផង ។
- អ្នកឆ្លងជំងឺអេដស៍នឹងត្រូវទទួលការរើសអើងពីសហគមន៍ និងខ្វះការគាំទ្រផ្លូវចិត្ត ។
- អេដស៍គ្មានថ្នាំព្យាបាលឱ្យជាសះស្បើយបានទេ គឺមានតែសេចក្តីស្លាប់ប៉ុណ្ណោះ ។

**សកម្មភាព**

សិស្សសង្ខេបពីឥរិយាបថមិនប្រឈមជាមួយ វីរុស HIV និងជំងឺអេដស៍

- នៅក្នុងទំនាក់ទំនងផ្លូវភេទដូចជា ការរៀបការ ភាពស្មោះត្រង់នៃដៃគូរួមភេទរវាងដៃគូទាំងពីរដែលមិនឆ្លងមេរោគបង្ហាញពីការប្រឈមតិចតួចណាស់ក្នុងការឈានទៅរកការឆ្លង វីរុស HIV។

- ចៀសវាងការប្រើប្រាស់គ្រឿងញៀនក៏ជាការសំខាន់សម្រាប់ការកាត់បន្ថយបញ្ហាប្រឈមនៃការឆ្លង វីរុស HIVដែរ។ អ្នកប្រើប្រាស់ម្ជុលរួមគ្នាដើម្បីចាក់គ្រឿងញៀនមានបញ្ហាប្រឈមខ្ពស់ក្នុងការឆ្លង វីរុស HIV។

អ្នករួមភេទជាមួយនឹងអ្នកសេពគ្រឿងញៀនក៏មានបញ្ហាប្រឈមខ្ពស់ផងដែរ។

*ជីវវិទ្យា ជំពូកទី ៤ មេរៀនទី ២*

**មេរៀនសង្ខេប**

- ជំងឺដែលឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតតាមរយៈភ្នាក់ងារបង្ករោគគេហៅថា ជំងឺឆ្លង ។
- ជំងឺឆ្លងមិនអាចកើតបាន នៅពេលយើងអនុវត្តអនាម័យទាំងបីយ៉ាង " ហូបស្អាត ផឹកស្អាត និងរស់នៅស្អាត" ឱ្យបានត្រឹមត្រូវ ។
- ជំងឺកាមរោគជាជំងឺដែលឆ្លងតាមរយៈការរួមភេទជាមួយដៃគូដែលមានផ្ទុកមេរោគ ។
- ជំងឺកាមរោគមានជំងឺប្រមេះទឹកបាយ ប្រមេះទឹកថ្លា ជំងឺសិរមាន់ ជំងឺស្វាយ ជំងឺសង់ម្វូ .. ។
- ជំងឺអេដស៍ឆ្លងតាមការរួមភេទជាមួយដៃគូដែលមានផ្ទុកមេរោគ ឆ្លងពីម្ដាយទៅទារកនៅក្នុងផ្ទៃ និងការប៉ះពាល់ឈាមរបស់អ្នកជំងឺ ។

**សំណួរ**

1. ចូរពន្យល់ពាក្យជំងឺឆ្លង និងរកឧទាហរណ៍ពីជំងឺឆ្លងដែលធ្លាប់ជួបប្រទះ ។
2. ហេតុអ្វីបានជាយើងត្រូវយកកន្សែងដៃខ្ទប់ច្រមុះ មាត់នៅពេលដែលយើងក្អក ឬកណ្ដាស់ ?
3. ដូចម្ដេចហៅថាជំងឺកាមរោគ ? ចូរឱ្យឧទាហរណ៍ ។
4. តើជំងឺកាមរោគអាចឱ្យមនុស្សស្លាប់ដែរឬទេ ?
5. តើជំងឺអេដស៍បង្កឡើងដោយសារមេរោគឈ្មោះអ្វី ? មេរោគនេះស្ថិតនៅកន្លែងណាខ្លះក្នុងសារពាង្គកាយរបស់មនុស្ស ?
6. ចូររៀបរាប់ពីរបៀបឆ្លង និងរបៀបមិនឆ្លងនៃជំងឺអេដស៍ ។
7. តើសកម្មភាពបង្ការណាមួយដែលមានប្រសិទ្ធិភាពបំផុតសម្រាប់យុវវ័យ ដើម្បីកុំឱ្យឆ្លងមេរោគអេដស៍និងកាមរោគ ?
8. តើការប្រើស្រោមអនាម័យពិតជាអាចបង្ការ ការឆ្លងមេរោគអេដស៍បាន 100% ដែរឬទេ ?

## វត្ថុបំណង (ត)

ពន្យល់ពីផលវិបាកនៃជំងឺឆ្លង និងជំងឺកាមរោគ ជាពិសេសជំងឺអេដស៍ និងជៀសវាងនូវសកម្មភាពផ្សេងៗដែលបណ្ដាលឱ្យមានការឆ្លងមេរោគ។

## សកម្មភាព

សិស្សធ្វើព្រឹត្តិប័ត្រអាស្រ័យនឹងខ្លឹមសារដែលពួកគេបានសិក្សា (ទាក់ទងនឹងការការពារពីការឆ្លងជំងឺអេដស៍ និងជំងឺកាមរោគ ហើយចែកក្រុមពិភាក្សាដោយក្នុងក្រុមមានភេទដូចគ្នា)។

សិស្សផ្លាស់ប្ដូរព្រឹត្តិប័ត្ររបស់ពួកគេទៅវិញទៅមក។

ឱ្យសិស្សឆ្លើយសំណួរក្នុងសៀវភៅពុម្ពដោយពុំអនុញ្ញាតឱ្យមើលឯកសារឡើយ។

## ឆ្លើយសំណួរ

1. ជំងឺឆ្លងគឺជាជំងឺដែលឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតតាមរយៈភ្នាក់ងារបង្កជំងឺ។ ជំងឺឆ្លងមានដូចជា ជំងឺផ្ដាសាយ ជំងឺរលាកថ្លើម ជំងឺរបេង ជាដើម។
2. យើងត្រូវយកកន្សែងដៃខ្ទប់ច្រមុះ មាត់នៅពេលដែលយើងក្អក ឬកណ្ដាស់ពីព្រោះជំងឺឆ្លងមួយចំនួនអាចឆ្លងទៅក្នុងខ្យល់។
3. ជំងឺកាមរោគគឺជាជំងឺដែលឆ្លងតាមរយៈការរួមភេទជាមួយដៃគូដែលមានផ្ទុកមេរោគ។ ជំងឺកាមរោគមានដូចជា ជំងឺប្រមេះទឹកបាយ ជំងឺប្រមេះទឹកថ្លា ជំងឺសិរមាន់ ជំងឺស្វាយ ជំងឺសង់ម្វូ...។
4. ជំងឺកាមរោគអាចបណ្ដាលឱ្យមនុស្សស្លាប់។
5. ជំងឺអេដស៍បង្កឡើងពី វីរុស HIV ។ មេរោគនេះស្ថិតនៅក្នុងប្រព័ន្ធភាពស៊ាំនៃសារពាង្គកាយមនុស្ស។
6. ជំងឺអេដស៍ឆ្លងតាមរយៈការរួមភេទជាមួយដៃគូដែលមានផ្ទុក វីរុសHIV ឆ្លងពីម្ដាយទៅទារកក្នុងផ្ទៃ និងតាមរយៈការប៉ះពាល់ឈាមរបស់អ្នកជំងឺ។ ជំងឺអេដស៍មិនឆ្លងតាមការចាប់ដៃគ្នា ការបរិភោគអាហារជាមួយគ្នា ការប្រើបង្គន់រួមគ្នា មូសខាំ ការលេងជាមួយគ្នា...។
7. សកម្មភាពបង្ការដែលមានប្រសិទ្ធិភាពបំផុតសម្រាប់យុវវ័យ ដើម្បីកុំឱ្យឆ្លង វីរុស HIV និងជំងឺកាមរោគគឺយុវវ័យមិនត្រូវឆាប់ប្រឡូកក្នុងការរួមភេទ។
8. ការប្រើស្រោមអនាម័យ មិនអាចបង្ការការឆ្លង វីរុស HIVបាន100 %ទេ។

## ចំណេះដឹងបន្ថែម និងសកម្មភាព & ការប្រើប្រាស់សម្ភារៈរបស់ SEAL

**ការចម្លងជំងឺសិប្បនិមិត្ត**

1. រៀបចំបំពង់សាកចំនួនប្រាំមួយ A B C និងA" B" C" ។ បំពង់សាកតែមួយគត់ដែលមានផ្ទុកសូលុយស្យុងអាមីដុង1% ក្នុងចំណោមបំពង់សាក A B C។ ចំពោះបំពង់សាកពីរផ្សេងទៀតក្នុងចំណោមបំពង់សាក A B និងC ដាក់តែទឹកប៉ុណ្ណោះ។ បំពង់សាកដែលដាក់ទឹកតំណាងឱ្យមនុស្សដែលមិនមានឆ្លងជំងឺ ហើយបំពង់សាកដែលដាក់សូលុយស្យុងអាមីដុងតំណាងឱ្យមនុស្សដែលឆ្លងជំងឺ។ គេមានបំពង់សាកA បំពង់សាកB និងបំពង់សាកC។ សិស្សមិនដឹងថាបំពង់សាកណាមានផ្ទុកអាមីដុងទេ។

**លើកទី 1**

2. ចាក់សូលុយស្យុងមួយតំណក់ពីបំពង់សាកA ចូលទៅក្នុបំពង់សាក A"។ បំពង់សាក A" មានទឹក 10ml រួចជាស្រេច។ បន្ទាប់ពីការបន្តក់សូលុយស្យុងមួយតំណក់រួច អ្នកកូរសូលូយស្យុងក្នុងបំពង់សាក A" ឱ្យសព្វ ហើយចាក់សូលុយស្យុងនោះ 5ml ទៅបំពង់សាក B"។

**លើកទី 2**

3. ចាក់សូលុយស្យុងមួយតំណក់ពីបំពង់សាកB ចូលទៅក្នុបំពង់សាក B"។ បន្ទាប់ពីការបន្តក់សូលុយស្យុងមួយតំណក់រួច អ្នកកូរសូលូយស្យុងក្នុងបំពង់សាក B" ឱ្យសព្វ ហើយចាក់សូលុយស្យុងនោះ2.5ml ទៅបំពង់សាក C"។

**លើកទី 3**

4. ចាក់សូលុយស្យុងមួយតំណក់ពីបំពង់សាក C ចូលទៅក្នុបំពង់សាក C"។




**តាមដានប្រភពជំងឺ**

5. ដើម្បីតាមដានប្រភពនៃការឆ្លងជំងឺ បណ្តក់សូលុយស្យុងអ៊ីយ៉ូតទៅក្នុងគ្រប់បំពង់សាកទាំងអស់។ ប្រសិនបើ សូលុយស្យុងរបស់អ្នកត្រូវបានឆ្លងជំងឺ សូលុយស្យុងនោះនឹងប្រែទៅជាពណ៌ខៀវ។

**ការពិភាក្សា**

ផ្អែកលើលទ្ធផល អ្នកអាចដឹងពីប្រភពនៃការឆ្លងជំងឺ តើបំពង់សាកណាជាប្រភពនៃការឆ្លងមេរោគ បំពង់សាកA បំពង់សាកB ឬបំពង់សាកC ។

*ការប្រើប្រាស់សម្ភាររបស់ SEAL*

សម្ភារផ្សេងៗទាក់ទងនឹងមេរៀនដែលអាចរកបាន

## តេស្តខ្លីសម្រាប់ជំងឺឆ្លង (រយៈពេល 1ម៉ោង)

ចូរជ្រើសរើសចម្លើយដែលត្រឹមត្រូវបំផុតបំពេញប្រយោគខាងក្រោម

1. វីរុស HIV អាចឆ្លងបានតាមរយៈ:

(ក) ការរួមភេទ (ខ) មូសខាំ (គ) ការចាប់ដៃ (ឃ) ការបរិភោគអាហារជាមួយគ្នា

2. វីរុស HIVធ្វើឱ្យខូចខាតប្រព័ន្ធភាពស៊ាំដោយសារ

(ក) ការបង្អាក់សកម្មភាពរបស់ម៉ាក្រូផាស

(ខ) ការបំផ្លាញកោសិកា T ជំនួយ

(គ) ការធ្វើឱ្យមានសកម្មភាពនៃការបង្កើតកោសិកា B

(ឃ) ចម្លើយទាំងអស់ខាងលើ

អ្នកស្រាវជ្រាវម្នាក់បានរាប់បរិមាណនៃវីរុស HIV និងកោសិកា T ក្នុងចំណោមអ្នកឆ្លងវីរុស HIV 120នាក់ អស់ពេលជាង10ឆ្នាំ។ ទិន្នន័យរបស់នាងត្រូវបានសង្ខេបដូចនៅក្នុងក្រាភិច។




3. ហេតុអ្វីបានជាកោសិកា T ថយចុះបន្ទាប់ពី 2 ឆ្នាំ?

(ក) វីរុស HIV ស្លាប់អស់បន្ទាប់ពី2 ឆ្នាំ។

(ខ) វីរុស HIV បំផ្លាញកោសិកា T។

(គ) កោសិកា T ផលិតជាតិពុល។

(ឃ) តំណាបរលាកមួយកើតឡើង។

4. តើមានអ្វីកើតឡើងចំពោះបរិមាណវីរុស HIV លើសពី 2ឆ្នាំរហូតដល់ 9ឆ្នាំ?

(ក) វាស្ថិតនៅប្រហាក់ប្រហែលដដែល បន្ទាប់មកវាកើនឡើងភ្លាមៗ

(ខ) វាស្ថិតនៅប្រហាក់ប្រហែលដដែល បន្ទាប់មកវាថយចុះភ្លាមៗ

(គ) វាកើនឡើងយ៉ាងថេរ

(ឃ) វាថយចុះយ៉ាងថេរ

5. តើសម្រាប់ការប្រែប្រួលបរិមាណវីរុស HIV ក្នុងអំឡុងឆ្នាំទី1 ជាតំណាបរំញោចអ្វី?

(ក) តំណាបប្រព័ន្ធភាពស៊ាំ

(ខ) តំណាបរលាក

(គ) ប្រព័ន្ធភាពស៊ាំអកម្ម

(ឃ) ការចាក់វ៉ាក់សាំងមេរោគ

# ចម្លើយ ពិន្ទុ និងការវិនិច្ឆ័យ

**សរុប 50 ពិន្ទុ**

1. (ក) ការរួមភេទ **10ពិន្ទុ**
2. (ខ) ការបំផ្លាញកោសិកា T ជំនួយ **10ពិន្ទុ**
3. (ខ) វីរុសHIV បំផ្លាញកោសិកាT **10ពិន្ទុ**
4. (គ) វាកើនឡើងយ៉ាងថេរ **10ពិន្ទុ**
5. (ក) តំណបប្រព័ន្ធភាពស៊ាំ **10ពិន្ទុ**

សំណួរនីមួយៗបញ្ជាក់ពីខ្លឹមសារខាងក្រោម។ សំណួរទី1 គឺការឆ្លងនៃវីរុស HIV។ សំណួរទី2 ជាយន្តការនៃការឆ្លងវីរុស HIV។ សំណួរទី3 ទី4 និងទី5 គឺជាជំនាញនៃការអានក្រាភិច។ បន្ថែមលើនេះ គឺជាយន្តការនៃវីរុស HIV។

ប្រសិនបើ ការធ្វើតេស្តមានពេលគ្រប់គ្រាន់ គ្រូគួរតែពន្យល់ពីយន្តការនៃវីរុសHIV និងរំឭកឡើងវិញពីការអានក្រាភិច។

## លក្ខណៈវិនិច្ឆ័យ

| ពិន្ទុ | លក្ខណៈវិនិច្ឆ័យ និងសំណូមពរសម្រាប់ការបង្រៀន |
|---|---|
| 0 - 20 | សិស្សខ្វះចំណេះដឹងមូលដ្ឋាន និងការយល់ដឹងពីជំងឺឆ្លង។ ពួកគេត្រូវតែបញ្ជាក់ពីជំងឺឆ្លង។ |
| 21 - 30 | សិស្សទទួលបានចំណេះដឹងមូលដ្ឋាន និងយល់ដឹងពីជំងឺឆ្លង។ ទោះជាយ៉ាងណា ពួកគេត្រូវតែរំឭកឡើងវិញពីយន្តការនៃជំងឺឆ្លង។ |
| 31 - 50 | សិស្សហាក់បីដូចជាមានកម្រិតនៃការយល់ដឹងពីជំងឺឆ្លងគ្រប់គ្រាន់។ គ្រូគួរតែឱ្យសិស្សគិតពីយន្តការនៃជំងឺឆ្លង។ |